# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## ដំណឹងជ្រើសរើសបេក្ខជនចូលរួម
## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2017 នៅប្រទេសជប៉ុន

លេខ: 22 PR-17/EoJ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយជម្រាបជូនថា ស្ថានទូតរួមសហការជាមួយក្រសួងអប់រំយុវជន និងកីឡា និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) នឹងរៀបចំជ្រើសរើសបេក្ខជនចូលរួមកម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2017 ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ នៅប្រទេសជប៉ុន។ ស្ថានទូតនឹងជ្រើសរើសនិស្សិត២៤រូប ដែលជានិស្សិតឆ្នាំទី៣គ្រប់ផ្នែកនៃសាកលវិទ្យាល័យទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំសិក្សា២០១៧-២០១៨ដែលដាក់ពាក្យដើម្បីប្រកួតធ្វើបទបង្ហាញ។

និស្សិតឆ្នាំទី៣ទាំងអស់ ដែលមានបំណងចូលរួមកម្មវិធីនេះ ត្រូវដាក់ពាក្យមកជាក្រុមដែលមានចំនួនសមាជិក៤នាក់ ត្រឹមថ្ងៃទី៧ ខែកញ្ញានេះ។ ថ្ងៃទី២៨ ខែកញ្ញា ស្ថានទូតនឹងប្រកាសអ្នកជាប់វគ្គជម្រុះនៃការដាក់ពាក្យចំនួន៤៨នាក់ ត្រូវនឹង១២ក្រុម ដើម្បីចូលរួមប្រកួតវគ្គផ្តាច់ព្រ័ត្រនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ នៅ CJCC ។ ការប្រឡងវគ្គផ្តាច់ព្រ័ត្រត្រូវវិនិច្ឆ័យតាមរយៈការធ្វើបទបង្ហាញជាក្រុមជាភាសាខ្មែរ រយៈពេល១០នាទី ក្រោមប្រធានបទ "**ប្រទេសកម្ពុជាដ៏ល្អអស្ចារ្យរបស់ខ្ញុំ**" ដោយពិនិត្យទៅលើខ្លឹមសារល្អ ភាពទាក់ទាញ និងការងារជាក្រុម។

កម្មវិធី JENESYS គឺជាកម្មវិធីផ្លាស់ប្តូរយុវជន ដែលបង្កើតឡើងដោយក្រសួងការបរទេសជប៉ុន ដើម្បីជម្រុញការយល់ដឹង និងការកសាងទំនុកចិត្តទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះ ក្រសួងការបរទេសជប៉ុនបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២០០០នាក់ហើយតាំងពីឆ្នាំ២០០៧មក។

សម្រាប់ព័ត៌មានបន្ថែមអំពីការជ្រើសរើស សូមចូមទៅកាន់គេហទំព័ររបស់ស្ថានទូតជប៉ុនប្រចាំកម្ពុជាដែលមានអាស័យដ្ឋាន៖ http://www.kh.emb-japan.go.jp/index-e.htm ឬក៏ទាក់ទងទៅកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុនប្រចាំកម្ពុជា ដែលមានលេខទូរស័ព្ទ០២៣ ២១៧ ១៦១ (#១១២២) ឬផ្ញើអ៊ីម៉េលទៅកាន់: info.jpn@pp.mofa.go.jp ។

---

Embassy of Japan in the Kingdom of Cambodia
Tel: 023 217 161, Fax: 023 216 162
Email: info.jpn@pp.mofa.go.jp, Official Website: www.kh.emb-japan.go.jp